**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ០៣៦៤ ព.ណ.វបណ.ស

ថ្ងៃព្រហស្បតិ៍ ៦កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពីអាហារូបករណ៍ ក្រោមកម្មវិធី "Australia Awards Scholarship"
## សម្រាប់ឆ្នាំសិក្សា ២០២១-២០២២

**យោង:** - លិខិតរបស់ Australia Awards ប្រចាំព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១។
- ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រី ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១។

វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ សូមគោរពជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការក្រោមឱវាទក្រសួងពាណិជ្ជកម្ម** មេត្តាជ្រាបថា៖ រដ្ឋាភិបាល អូស្ត្រាលី បានផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជូនដល់មន្ត្រីរាជការ នៃក្រសួងពាណិជ្ជកម្មសម្រាប់ឆ្នាំសិក្សា ២០២១-២០២២។

កម្មវិធីអាហារូបករណ៍នេះ ចាប់ផ្តើមទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១។ ចំពោះបេក្ខជនដែលមានចំណាប់អារម្មណ៍លើកម្មវិធីអាហារូបករណ៍ខាងលើ អាចដាក់ពាក្យស្នើសុំអាហារូបករណ៍តាមរយៈគេហទំព័រ www.australiaawardscambodia.org.។ ដើម្បីទទួលបានព័ត៌មានលម្អិតសូមទំនាក់ទំនង តាមរយៈលេខទូរស័ព្ទ: ០១២ ៦៣៥ ៣០៦ ឬសារអេឡិចត្រូនិច info@australiaawardscambodia.org.។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការក្រោមឱវាទក្រសួងពាណិជ្ជកម្ម** មេត្តាជ្រាបជាព័ត៌មាន។

**សូមអរគុណ!**